ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

3

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០៦ ស រ ណ ន

## សារាចរណែនាំ
## ស្តីពី
## ការធ្វើអាជីវកម្មល្បែងកំសាន្តអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ
## ( ស្លុតម៉ាស៊ីន )

ស្ថានភាពនយោបាយ និងសេដ្ឋកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានលក្ខណៈប្រសើរ ធ្វើឱ្យការអភិវឌ្ឍលើគ្រប់វិស័យបានបោះជំហានទៅមុខគួរឱ្យកត់សំគាល់ ហើយការពារសន្តិសុខ និងសុវត្ថិភាពជូនប្រជាពលរដ្ឋក៏ត្រូវបាន ពង្រឹងជាបន្តបន្ទាប់ ។ កត្តាទាំងនេះធ្វើអោយចំនួនភ្ញៀវទេសចរបរទេស ចូលមកទស្សនានៅព្រះរាជាណាចក្រកម្ពុជា យើងកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ។

កន្លងមក ដើម្បីបំរើសេចក្តីត្រូវការ និងការកំសាន្តសប្បាយ របស់ភ្ញៀវទេសចរបរទេស និងតាមសំណើរបស់ក្រុមហ៊ុនមួយចំនួន រាជរដ្ឋាភិបាលកម្ពុជាបានអនុញ្ញាតជាគោលការណ៍ឱ្យបើកមជ្ឈមណ្ឌលកំសាន្ត ឬក្លឹបកំសាន្តបំពាក់ ដោយម៉ាស៊ីនអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ ( មិនមែនកាស៊ីណូ ) នៅតាមសណ្ឋាគារនៅក្នុងរាជធានី និងខេត្ត-ក្រុងមួយចំនួន ។ ប៉ុន្តែរាជរដ្ឋាភិបាលពិនិត្យឃើញថា ក្រុមហ៊ុនដែលបាន ទទួលអាជ្ញាប័ណ្ណឱ្យបើកធ្វើអាជីវកម្មល្បែង កំសាន្តអេឡិចត្រូនិច និងមេកានិច (ស្លុតម៉ាស៊ីន) មួយចំនួន មិនបានគោរពទៅតាមសៀវភៅបន្ទុក ។ ប្រការទាំង នេះបានធ្វើឱ្យប៉ះពាល់ដល់ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈនៅក្នុងរាជធានីភ្នំពេញ និង ខេត្ត-ក្រុងមួយ ចំនួនទៀត ។

ដូច្នេះ ដើម្បីធ្វើការគ្រប់គ្រងអាជីវកម្មល្បែងកំសាន្តអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ (ស្លុតម៉ាស៊ីន) ប្រកបដោយប្រសិទ្ធភាព និងស្របតាមបទដ្ឋានបច្ចេកទេស រាជរដ្ឋាភិបាលកម្ពុជាដាក់វិធានការ ឱ្យអនុវត្តដូចខាងក្រោម:

១- បន្ទាប់ពីមានការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាលត្រូវមានអាជ្ញាប័ណ្ណធ្វើអាជីវកម្មពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

២- ត្រូវមានទីតាំងនៅក្នុងសណ្ឋាគារ ដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវពីក្រសួងទេសចរណ៍ និងមិនអនុញ្ញាតឱ្យមានសាខាឡើយ ។ ចំពោះក្រុមហ៊ុន ដែលមានអាជ្ញាប័ណ្ណធ្វើអាជីវកម្មហើយ មានទីតាំងមិនស្ថិតនៅក្នុងសណ្ឋាគារ ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបញ្ឈប់សកម្មភាពអាជីវកម្មបណ្តោះអាសន្ន និងតំរូវឱ្យក្រុមហ៊ុនរើទីតាំងរបស់ខ្លួនចូលទៅក្នុងសណ្ឋាគារ

ក្នុងរយៈពេល ៦ខែ យ៉ាងយូរ គិតចាប់ពីថ្ងៃចេញសារាចរណែនាំនេះ ។ ក្នុងករណីមិនបំពេញតាមលក្ខខ័ណ្ឌនេះ ក្រសួងមហាផ្ទៃ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបញ្ឈប់សកម្មភាពអាជីវកម្ម និងដកហូតអាជ្ញាប័ណ្ណជាស្ថាពរ ។

៣- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវដកហូតអាជ្ញាប័ណ្ណចំពោះក្រុមហ៊ុនទាំងឡាយណា ដែលមិនបាន អនុវត្តទៅតាមប្រកាសលេខ ២៤៧សហវ.ប្រក និងលក្ខខ័ណ្ឌផ្តល់អាជ្ញាប័ណ្ណដូចមានចែងក្នុងសៀវភៅបន្ទុក និងចំណុច ២ ខាងលើ ។

៤- ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវចាត់វិធានការបង្ក្រាបជាបន្ទាន់ ចំពោះមជ្ឈមណ្ឌល កំសាន្តអេឡិចត្រូនិចនិងមេកានិច គ្រប់ប្រភេទ(ស្លុតម៉ាស៊ីន) ដែលគ្មានការអនុញ្ញាតពីរាជរដ្ឋាភិបាល និងគ្មានអាជ្ញាប័ណ្ណចេញដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

៥- មិនអនុញ្ញាតឱ្យប្រជាពលរដ្ឋខ្មែរចូលលេងជាដាច់ខាត ។ បើមានការខុសឆ្គងប្រការណាមួយ ដូចជា មានអនុញ្ញាតឱ្យប្រជាពលរដ្ឋខ្មែរចូលលេង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវដកអាជ្ញាប័ណ្ណបញ្ឈប់អាជីវ-កម្មក្នុងរយៈពេល ២៤ ម៉ោងក្រោយគំហើញ ។

៦- អាជ្ញាធរដែនដីខេត្ត-ក្រុង ព្រមទាំងស្ថាប័នផ្សេងទៀត ពុំមានសិទ្ធិចេញលិខិតអនុញ្ញាតឱ្យបើកមជ្ឈ-មណ្ឌលកំសាន្តអេឡិចត្រូនិច និងមេកានិចគ្រប់ប្រភេទ (ស្លុតម៉ាស៊ីន) ឡើយ ។

៧- ក្នុងករណីចាំបាច់ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំបែបបទប្តឹងទៅ ស្ថាប័នតុលាការចំពោះម្ចាស់មជ្ឈមណ្ឌលកំសាន្តអេឡិចត្រូនិច និងមេការនិចគ្រប់ប្រភេទ (ស្លុតម៉ាស៊ីន)ដែល អនុវត្តផ្ទុយពីសារាចរណែនាំនេះ ។

ទទួលបានសារាចរនេះ ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងទេសចរណ៍ អាជ្ញាធរ ដែនដីខេត្ត-ក្រុង ព្រមទាំងស្ថាប័នពាក់ព័ន្ធ ត្រូវយកចិត្តទុកដាក់សហការអនុវត្តសារាចរណែនាំនេះអោយ ទទួល បានប្រសិទ្ធិភាពខ្ពស់ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០០៨

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ចម្លងជូនៈ**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងទេសចរណ៍ ‹ ដើម្បីអនុវត្ត ›
- គ្រប់សាលាខេត្ត-ក្រុង ‹ ដើម្បីសហការអនុវត្ត ›
- ឯកសារ-កាលប្បវត្តិ